**NEWS RELEASE**

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

ទិវាអន្តរជាតិលុបបំបាត់និទណ្ឌភាព នៅថ្ងៃសៅរ៍ ទី ២៣ ខែ វិច្ឆិកា

# បំបែកភាពស្ងៀមស្ងាត់: ក្រុមអ្នកជំនាញការអង្គការសហប្រជាជាតិនិយាយថា ពេលវេលាពង្រឹងតួនាទីរបស់អង្គការសហប្រជាជាតិ ក្នុងការបញ្ចប់និទណ្ឌភាព បានមកដល់ហើយ

**ហ្សឺណែវ (២២ វិច្ឆិកា ២០១៣)** នៅថ្ងៃនេះ ក្រុមអ្នកជំនាញការផ្នែកសិទ្ធិមនុស្សឯករាជ្យរបស់អង្គការសហប្រជាតិមួយក្រុម បានអំពាវនាវឲ្យអង្គការសហប្រជាជាតិដើរតួនាទីខ្លាំងជាងនេះក្នុងការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព និង បានជំរុញអោយរដ្ឋជាសមាជិកផ្តល់ការគាំទ្រកាន់តែខ្លាំងឡើងថែមទៀត ព្រមទាំងពង្រឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីធានាការទទួលខុសត្រូវ និង យុត្តិធម៌ ចំពោះការរំលោភបំពានសិទ្ធិមនុស្ស រួមទាំងបទល្មើសធ្ងន់ធ្ងរ។

ពួកគេបានគូសបញ្ជាក់ថា “ការបញ្ចប់និទណ្ឌភាពតម្រូវឲ្យមានការពិនិត្យ ការចោទប្រកាន់ និង ការផ្តន្ទាទោសធ្ងន់ធ្ងរជាងនេះទៀត ហើយគ្មានស្ថាប័នអន្តរជាតិណាល្អជាងអង្គការសហប្រជាជាតិក្នុងការរួមចំណែកដល់គោលដៅនេះឡើយ”។ “ពេលវេលាបានមកដល់ហើយសម្រាប់អង្គការសហប្រជាជាតិ ក្នុងការដើរតួនាទីម៉ឺងម៉ាត់ប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព និង យកចិត្តទុកដាក់ទៅលើគ្រប់ទិដ្ឋភាពនៃបញ្ហា រួមទាំងភាពចុះខ្សោយនៃនីតិរដ្ឋ និង ការរំលោភបំពានគោលការណ៍ទូទៅនៃយុត្តិធម៌”។

ដោយស្វាគមន៍គំនិតផ្តួចផ្តើមរបស់សង្គមស៊ីវិលក្នុងការរៀបចំយកថ្ងៃទី ២៣ ខែ វិច្ឆិកា ជាថ្ងៃរំលឹកខួបទិវាអន្តរជាតិលុបបំបាត់និទណ្ឌភាពប្រចាំឆ្នាំ ក្រុមអ្នកជំនាញការផ្នែកសិទ្ធិមនុស្សបានរំលឹកថា ប្រមុខរដ្ឋ និង រដ្ឋាភិបាល បានសន្យាធានាថាមិនអត់ឱនដល់និទណ្ឌភាពនៃការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្ស និង ច្បាប់មនុស្សធម៌អន្តរជាតិ ហើយធ្វើការស៊ើបអង្កេត ចោទប្រកាន់ និង ដាក់ទណ្ឌកម្មយ៉ាងត្រឹមត្រូវលើការរំលោភបំពានទាំងនេះ ដូចមានចែងក្នុងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីនីតិរដ្ឋ ដែលអនុម័តនៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២។

ក្រុមអ្នកជំនាញការបានរំលឹកថា រដ្ឋត្រូវយកអ្នកដែលពុំបានការពារ និង ទប់ស្កាត់ ក៏ដូចជាអ្នកដែលប្រព្រឹត្តរំលោភសិទ្ធិមនុស្ស រួមទាំងសិទ្ធិនារី និង ក្រុមរងគ្រោះផ្សេងទៀត មកទទួលខុសត្រូវ។ ពួកគេបានបន្ថែមទៀតថា "ការប្រយុទ្ធប្រឆាំងនិទណ្ឌភាពមិនត្រឹមតែបញ្ជាក់ពីកាតព្វកិច្ចរបស់រដ្ឋក្នុងការស៊ើបអង្កេតចំពោះការរំលោភបំពាន និង ចាត់វិធានការសមស្របចំពោះជនល្មើស និង ជនរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានាចំពោះសិទ្ធិដែលមិនអាចដកបាន ក្នុងការយល់ដឹងពីការពិតអំពីការរំលោភបំពាន ព្រមទាំងចាត់វិធានការចាំបាច់ផ្សេងទៀត ដើម្បីទប់ស្កាត់កុំឲ្យកើតឡើងវិញម្តងទៀតផង"។

ពួកគេបានិយាយថា "កិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហានិទណ្ឌភាព ចាំបាច់ទាមទារនូវតម្លាភាព និង ការទទួលខុសត្រូវរបស់រដ្ឋទាំងអស់ និង តួអង្គដែលមិនមែនជារដ្ឋ ដោយរួមទាំងមិនត្រឹមតែកងកម្លាំងស្រលាញ់យោធា ទាហានស៊ីឈ្នួល ក្រុមហ៊ុនយោធាឯកជន និងភេរវករប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្រុមហ៊ុនអន្តរកាលទៀតផង"។

ក្រុមអ្នកជំនាញការឯករាជ្យបានបញ្ជាក់ថា "គោលដៅបញ្ចប់និទណ្ឌភាពមានគោលបំណងរកយុត្តិធម៌ប៉ុណ្ណោះ ពុំមានគោលបំណងសងសឹកទេ"។ "វាតម្រូវឲ្យមានភាពសត្យានុម័តពិតប្រាកដ និង ភាពមិនអាចជ្រើសរើសបាន ក្នុងការកំណត់អត្តសញ្ញាណពីការរំលោភបំពានដែលពុំទាន់បានដោះស្រាយ"។

ពួកគេបាននិយាយថា "ការដោះស្រាយបញ្ហាប្រឈមនៃនិទណ្ឌភាពមិនមែនជាផ្លូវតែមួយសម្រាប់រកយុត្តិធម៌របស់អ្នកជ័យជំនះ និង ការផ្តន្ទាទោសអ្នកមានកំហុសក្នុងចំណោមអ្នកបរាជ័យនោះទេ"។ "ត្រូវតែស្វែងរកដំណោះស្រាយនៅក្នុងការអនុវត្តច្បាប់ស្មើៗគ្នា ព្រមទាំងការប្តេជ្ញាចិត្តដើម្បីទទួលបានភាពសមស្របរបស់អ្នកមានអំណាច និង អ្នកទន់ខ្សោយ ដូចៗគ្នា"។

ក្រុមអ្នកជំនាញការសិទ្ធិមនុស្សបានកត់សំគាល់ឃើញថា ការប្រយុទ្ធប្រឆាំងនិទណ្ឌភាពតម្រូវឲ្យរដ្ឋាភិបាលធានាសិទ្ធិទទួលបានយុត្តិធម៌គ្រប់ៗគ្នា ដើម្បីឲ្យអ្នកគ្រប់គ្នាទទួលបានព័ត៌មានហើយឈប់ប្រើសន្តិសុខជាតិ អភ័យឯកសិទ្ធិ ឬ វិធានការផ្សេងទៀត ដើម្បីបិទបាំងអំពើឧក្រិដ្ឋតទៅទៀត។

ពួកគេបានសន្និដ្ឋានថា "សិទ្ធិជាសកលក្នុងការទទួលបានព័ត៌មានផ្សេងគ្នា និង ទុកចិត្តបានប្រព័ន្ធយុត្តិធម៌ក្នុងស្រុកប្រកបដោយប្រសិទ្ធភាព សកលភាវូបនីយកម្មនៃយុត្តាធិការរបស់

តុលាការព្រហ្មទណ្ឌអន្តរជាតិ និង ការសម្រេចបានជាក់ស្តែងនូវសិទ្ធិទទួលបានការពិត គឺជាល័ក្ខខ័ណ្ឌចាំបាច់ ដើម្បីលុបបំបាត់និទណ្ឌភាព”។

(*) **ក្រុមអ្នកជំនាញការ:** លោក Alfred de Zayas អ្នកជំនាញការឯករាជ្យផ្នែកលើកកម្ពស់**សណ្តាប់ធ្នាប់អន្តរជាតិ**បែបប្រជាធិបតេយ្យ និង ស្មើភាពគ្នា។ លោក Anand Grover អ្នករាយការណ៍ពិសេសផ្នែកសិទ្ធិរបស់មនុស្សគ្រប់រូប ក្នុងការទទួលបាន**សុខភាព**ផ្លូវកាយ និង ផ្លូវចិត្ត ក្នុងកម្រិតខ្ពស់បំផុតដែលអាចទទួលយកបាន។ លោក Anton Katz ប្រធានអ្នករាយការណ៍នៃក្រុមការងារផ្នែកប្រើប្រាស់**ទាហាន ស៊ីឈ្នួល** ដែលជាមធ្យោបាយរំលោភសិទ្ធិមនុស្ស និង រារាំងដល់ការអនុវត្តសិទ្ធិរបស់មនុស្សក្នុងការទទួលការសម្រេចដោយខ្លួនឯង។ លោកស្រី Catarina de Albuquerque អ្នករាយការណ៍ពិសេសផ្នែកសិទ្ធិមនុស្សក្នុងការទទួលបាន**ទឹក**ពិសាដោយសុវត្ថិភាព និង **អនាម័យ**។ លោក Frank La Rue អ្នករាយការណ៍ពិសេសផ្នែកលើកកម្ពស់ និង ការពារសិទ្ធិ**សេរីភាពនៃគំនិត និង បញ្ចេញមតិ**។ លោកស្រី Gabriela Knaul អ្នករាយការណ៍ពិសេសផ្នែក**ឯករាជ្យភាពរបស់ចៅក្រម និង មេធាវី**។ លោកស្រី Gulnara Shahinian អ្នករាយការណ៍ពិសេសផ្នែកទម្រង់**ទាសភាព**ទំនើប។ លោក Heiner Bielefeldt អ្នករាយការណ៍ពិសេសផ្នែក**សេរីភាពសាសនា ឬ ជំនឿ**។ លោក Juan Mendez អ្នករាយការណ៍ពិសេសផ្នែក**ទារុណកម្ម** និង អំពើការប្រព្រឹត្តិសាហាវព្រៃផ្សៃ អមនុស្សធម៌ ឬ ថោកទាប ឬ ទណ្ឌកម្មផ្សេងទៀត។ លោក Maina Kiai អ្នករាយការណ៍ពិសេសផ្នែកសិទ្ធិសេរីភាពនៃ**ការជួបជុំគ្នាដោយសន្តិវិធី និង សមាគម**។ លោកស្រី Magdalena Sepulveda Carmona អ្នករាយការណ៍ពិសេសផ្នែក**ភាពក្រីក្របំផុត** និង សិទ្ធិមនុស្ស។ លោកស្រី Margaret Sekaggya អ្នករាយការណ៍ពិសេសផ្នែកស្ថានភាព**អ្នកការពារសិទ្ធិមនុស្ស**។ លោកស្រី Najat Maalla M'jid អ្នករាយការណ៍ពិសេសផ្នែក**លក់ដូរកុមារ** ពេស្យាចារកុមារ និង រូបអាសអាភាសកុមារ។ លោក Pablo de Greiff អ្នករាយការណ៍ពិសេសផ្នែកលើកកម្ពស់**ការពិត** យុត្តិធម៌ សំណង និង ការធានាមិនឲ្យកើតឡើងម្តងទៀត។ លោក Rashida Manjoo អ្នករាយការណ៍ពិសេសផ្នែក**អំពើហិង្សាប្រឆាំងនឹងនារី** ហេតុ និង ផលរបស់វា។ ព្រមទាំង ក្រុមការងារផ្នែក**ការបាត់ខ្លួនដោយបង្ខំ ឬ មិនស្ម័គ្រចិត្ត**។

*Learn more:* http://www.ohchr.org/EN/HRBodies/SP/Pages/Welcomepage.aspx
*Check the UN Declaration on the rule of law:* http://www.un.org/ga/search/view_doc.asp?symbol=A/67/L.1
*For more information and **media requests**, please contact Pol Planas (+41 22 9179657 / pplanas@ohchr.org).*

For **media inquiries** related to other UN independent experts:
Xabier Celaya, UN Human Rights – Media Unit (+ 41 22 917 9383 / xcelaya@ohchr.org)

**UN Human Rights, follow us on social media:**
**Facebook:** https://www.facebook.com/unitednationshumanrights
**Twitter:** http://twitter.com/UNrightswire
**Google+** gplus.to/unitednationshumanrights
**YouTube:** http://www.youtube.com/UNOHCHR
**Storify:** http://storify.com/UNrightswire
**Watch "20 years of human rights - the road ahead":** http://youtu.be/yW7s-Q8S14E